**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**

ជាន់ទី១២ អាគារ Exchange Square
ផ្លូវលេខ១០៦ កែងផ្លូវលេខ៦១
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

AIA.COM.KH

# សេចក្ដីប្រកាសសារព័ត៌មាន

## អេ អាយ អេ ខេមបូឌា  ចាប់ដៃគូជាមួយ MEDIX ផ្ដល់ការប្រឹក្សា និងណែនាំលើការព្យាបាលក្នុងករណីធ្វើរោគវិនិច្ឆ័យមានជំងឺមហារីក

**ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១៖** ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អេ អាយ អេ ខេមបូឌា  បានចាប់ដៃគូជាមួយ MEDIX ដែលជាក្រុមហ៊ុនលំដាប់ថ្នាក់ពិភពលោកឈានមុខគេ  ផ្ដល់សេវា  គ្រប់គ្រងផ្នែកសុខភាព។  ការចាប់ដៃគូនេះគឺដើម្បីផ្ដល់ជូនសេវាប្រឹក្សា  និងណែនាំ ជូនអតិថិជនអំពីការព្យាបាល នៅពេលអតិថិជនមានការសង្ស័យ ឬធ្វើរោគវិនិច្ឆ័យឃើញថាមានជំងឺមហារីក ។

តាមរយៈការចាប់ដៃគូនេះ  ដែលគោលបំណងដើម្បីឲ្យអតិថិជនទទួលបានលទ្ធផល  ព្យាបាលកាន់តែប្រសើរ  អតិថិជនរបស់  អេ អាយ អេ ទាំងថ្មី ទាំងចាស់នឹងទទួលបាន សេវាគ្រប់គ្រង និងប្រឹក្សាការព្យាបាលផ្ទាល់ខ្លួន( PMCM )របស់ក្រុមហ៊ុន MEXDIX  ដែលនេះជាសេវាផ្ដល់ការប្រឹក្សា និងណែនាំដល់អតិថិជន ចាប់តាំងពីពេលមានសង្ស័យថាមានជំងឺមហារីក ដំណាក់កាលធ្វើរោគវិនិច្ឆ័យ ដំណាក់កាលព្យាបាល និងរហូតដល់ជាសះស្បើយ។

សេវាកម្មបន្ថែមនេះ គឺជាការផ្ដល់ជូនផ្ដាច់មុខដល់ដល់អតិថិជន អេ អាយ អេ ដែលមានលក្ខខណ្ឌគ្រប់គ្រាន់ដោយឥតគិតថ្លៃ ហើយសេវាកម្មនេះនឹងផ្ដល់ទំនុកចិត្តជូនពួកគាត់ដើម្បី ទទួលយកការព្យាបាលនៅគ្រប់ទីកន្លែងក្នុងពិភពលោក។ អតិថិជនដែលមានសិទ្ធិទទួលបាន  សេវាគ្រប់គ្រង  និងប្រឹក្សាការព្យាបាលផ្ទាល់ខ្លួន( PMCM )នេះនឹងទទួលបានការប្រឹក្សា  ផ្ទាល់ជាមួយវេជ្ជបណ្ឌិត  និងគិលានុបដ្ឋាយិកាមួយរូប ដែលចាត់តាំងដោយក្រុមហ៊ុន MEDIX។   តាមរយៈការចាត់តាំងនេះ អតិថិជននឹងទទួលបានការប្រឹក្សាពីបណ្ដាញអ្នកឯកទេសលំដាប់ថ្នាក់ពិភពលោកឈានមុខគេជាង ៤.០០០ នាក់ និងមន្ទីរពេទ្យអន្តរជាតិកំពូលៗចំនួន ២.០០០ កន្លែង។ អតិថិជននឹងទទួលបានការណែនាំ និងការគាំទ្រ ទាំងផ្នែកវេជ្ជសាស្ត្រ និងផ្លូវចិត្តជាបន្តបន្ទាប់ ។

ជាមួយ សេវាគ្រប់គ្រង និងប្រឹក្សាការព្យាបាលផ្ទាល់ខ្លួន( PMCM )អតិថិជនរបស់ អេ អាយ អេ អាចធ្វើការសម្រេចចិត្តទទួលយកការព្យាបាលដ៏ត្រឹមត្រូវ   ដោយផ្អែកលើការណែនាំរបស់អ្នកឯកទេសទាំងក្នុងតំបន់   និងអន្តរជាតិជាមួយជម្រើសព្យាបាលដែលស័ក្តិសមសម្រាប់ អតិថិជន រួមទាំងការប្រឹក្សា និងណែនាំជាបន្តបន្ទាប់។

លោកស្រី Pauline Teoh អគ្គនាយិកាក្រុមហ៊ុន  អេ អាយ អេ ខេមបូឌា បានមានប្រសាសន៍ថា" គ្មាននរណាម្នាក់ត្រូវធ្វើការសម្រេចចំពោះបញ្ហាធ្ងន់ធ្ងរ និងលំបាក ទាំងដែលគ្មានព័ត៌មាន និងចំណេះដឹងត្រឹមត្រូវនោះឡើយ ជាពិសេសនៅពេលប្រឈមមុខនឹងស្ថានភាពជំងឺដែលគំរាមកំហែងដល់អាយុជីវិត ដូចជាជំងឺមហារីក ។

តាមរយៈភាពជាដៃគូយុទ្ធសាស្ត្រនេះ យោងតាមលទ្ធផលដែលបានបង្ហាញកន្លងមករបស់ MEDIX  អេ អាយ អេ ខេមបូឌា នឹងផ្ដល់សេវាកម្មល្អបំផុតជូនអតិថិជន  ដើម្បីកាត់បន្ថយការព្រួយបារម្ភផ្នែកហិរញ្ញវត្ថុ  និងក្ដីបារម្ភផ្សេងៗ  នៅគ្រប់ជំហាននៃដំណើរការការព្យាបាលរបស់ពួកគាត់។ ដូច្នេះ អតិថិជនអាចផ្ដោតអារម្មណ៍ និងយកចិត្តទុកដាក់តែលើការថែទាំសុខភាពឲ្យល្អ និងជាសះស្បើយ ។

"ជាមួយនឹង សេវាគ្រប់គ្រង និងប្រឹក្សាការព្យាបាលផ្ទាល់ខ្លួន(PMCM) អតិថិជនអាច សម្រេចចិត្តជ្រើសយកជម្រើសព្យាបាលល្អបំផុត និងស្របតាមតម្រូវការរបស់ពួកគាត់។ ជាមួយនឹងអត្ថប្រយោជន៍ជាច្រើន ដែលទទួលទំនុកចិត្តពីអតិថិជនជាបន្តបន្ទាប់ ការចាប់ដៃគូជាមួយ MEDIX ទៅលើជំនាញគ្រប់គ្រងការព្យាបាលដែលគ្មានគូប្រៀបរបស់ពួកគេនៃ សេវាគ្រប់គ្រង និងប្រឹក្សាការព្យា បាលផ្ទាល់ខ្លួន(PMCM) នឹងជួយឲ្យ អេ អាយ អេ បំពេញតាមការសន្យាក្នុងរបស់ខ្លួន ក្នុងការជួយឱ្យមនុស្សគ្រប់រូបរស់នៅប្រកបដោយសុខភាព និងជីវិតកាន់តែប្រសើរ។

លោកស្រី Sigal Atzmon ស្ថាបនិក និងជាអគ្គនាយិការបស់ Medix បានចែករំលែកនូវអារម្មណ៍ស្រដៀងគ្នាដោយនិយាយថា "ភាពជាដៃគូនេះមិនត្រឹមតែធ្វើឲ្យ អេ អាយ អេ ខេមបូឌា កាន់តែមានភាពលេចធ្លោប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តល់ជូនអតិថិជននូវជម្រើសព្យាបាលដែលមានលក្ខណៈផ្ទាល់ខ្លួន ច្បាស់លាស់ និងគុណភាពខ្ពស់ផងដែរ។ កត្តាទាំងនេះ នឹងជួយត្រួសត្រាយផ្លូវជូនអតិថិជនក្នុងដំណើរនៃការព្យាបាលដើម្បីទទួលបានលទ្ធផលដ៏ប្រសើរ។

ខណៈពេលដែលភាពជាដៃគូនេះធ្វើឲ្យគោលជំហររបស់ អេ អាយ អេ ចំពោះការយកចិត្តទុក ដាក់លើសុខុមាលភាពអតិថិជន មានភាពលេចធ្លោខុសពីក្រុមហ៊ុនធានារ៉ាប់រងដទៃទៀត ហើយនោះ  ចំនុចសំខាន់មួយទៀតគឺជួយអតិថិជនឲ្យទទួលបានព័ត៌មានគ្រប់គ្រាន់ពីស្ថានភាពសុខភាព  ដើម្បីធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវមួយ ដែលអាចឲ្យជីវិតពួកគាត់ផ្លាស់ប្តូរទៅ រកភាពកាន់តែប្រសើរ។

សព្វថ្ងៃនេះ ការធានារ៉ាប់រងគឺមិនត្រឹមតែផ្តល់សំណងប៉ុណ្ណោះទេ ហើយយើងមានមោទនភាពចំពោះMEDIX ដែលដើរតួសំខាន់ក្នុងការពង្រឹងទំនាក់ទំនងរវាង អេ អាយ អេ និងអតិថិជនរបស់ខ្លួន ដើម្បីឲ្យពួកគាត់មានទំនុកចិត្ត ភាពច្បាស់លាស់ និងការគ្រប់គ្រងដែលត្រូវការ ដើម្បីជួយឱ្យពួកគាត់មានជីវិតកាន់តែប្រសើរ ។

ដើម្បីស្វែងយល់ពីរបៀបដែល សេវាគ្រប់គ្រង និងប្រឹក្សាការព្យាបាលផ្ទាល់ខ្លួន(PMCM) អាចធ្វើឱ្យជីវិតផ្លាស់ប្តូរកាន់តែប្រសើរ សូមទាក់ទងទីប្រឹក្សាផែនការអាយុជីវិត ឬ ផ្នែកបម្រើសេវាអតិថិជន អេ អាយ អេ តាមរយៈលេខ ០៨៦ ៩៩៩ ២៤២។

**អំពី អេ អាយ អេ ខេមបូឌា**

AIA Group Limited និង បុត្រសម្ព័ន្ធរបស់ខ្លួន (រួមគ្នារវាង "AIA" ឬ "Group") បានចុះបញ្ជីជាសាធារណៈធំជាងគេក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។

សម្ព័ន្ធ AIA មានវត្តមាននៅក្នុងទីផ្សារចំនួន១៨នៅអាស៊ីប៉ាស៊ីហ្វិក ដែលក្នុងនោះមានសាខា និងបុត្រសម្ព័ន្ធដែលជាកម្មសិទ្ធិទាំងស្រុង នៅហុងកុង ចិន ថៃ សិង្ហបុរី ម៉ាឡេស៊ី អូស្ត្រាលី កម្ពុជា ឥណ្ឌូនេស៊ី ភូមា ហ្វីលីពីន កូរ៉េខាងត្បូង តៃវ៉ាន់ វៀតណាម ប្រ៊ុយណេ ម៉ាកាវ ណូវែលហ្សេឡង់ព្រមទាំងបុត្រសម្ព័ន្ធដែលជាកម្មសិទ្ធិ៩៩ភាគរយនៅស្រីលង្កា និងក្រុមហ៊ុនសម្ព័ន្ធអាជីវកម្ម៤៩ភាគរយនៅឥណ្ឌា។

អាជីវកម្ម ដែលបានក្លាយទៅជា AIA បច្ចុប្បន្ននេះ បានចាប់ផ្តើមមួយសតវត្សកន្លងមក ក្នុងឆ្នាំ១៩១៩ នៅទីក្រុងសៀងហៃ។ AIA គឺជាក្រុមហ៊ុនឈានមុខគេនៅតំបន់អាស៊ីប៉ាស៊ីហ្វិក (លើកលែងជប៉ុន) ដោយយោងលើបុព្វលាភធានារ៉ាប់រងជីវិត និងឈានមុខគេនៅក្នុងទីផ្សារភាគច្រើនរបស់ខ្លួន។ AIA មានទ្រព្យសរុប២៨៤ពាន់លានដុល្លាអាមេរិក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

AIA ឆ្លើយតបទៅនឹងតម្រូវការសន្សំរយៈពេលវែង និងការការពារជាលក្ខណៈបុគ្គលដោយផ្តល់ជូននូវផលិតផល និងសេវាកម្មជាច្រើនរួមមានធានារ៉ាប់រងអាយុជីវិត ធានារ៉ាប់រងគ្រោះថ្នាក់និង សុខភាព និងផែនការសន្សំ។ សម្ព័ន្ធ AIA ក៏មានផ្តល់អត្ថប្រយោជន៍សម្រាប់បុគ្គលិក ឥណ្ឌាទានជីវិត និង សេវាកម្មសោធនទៅកាន់អតិថិជនជាសារជីវកម្មនានា។ តាមរយៈបណ្តាញដ៏ទូលំទូលាយនៃភ្នាក់ងារ ដៃគូ និងធនធានមនុស្សនានាទូទាំងអាស៊ីប៉ាស៊ីហ្វិក AIA បម្រើម្ចាស់បណ្ណសន្យាធានារ៉ាប់រងច្រើនជាង៣៦លានបណ្ណ និងសមាជិកទទួលអត្ថប្រយោជន៍ធានារ៉ាប់រងតាមក្រុមហ៊ុននានាច្រើនជាង១៦លាននាក់។

AIA Group Limited ត្រូវបានចុះបញ្ជីនៅក្នុង The Stock Exchange of Hong Kong Limited ដោយមានលេខកូដមូលបត្រលេខ "១២៩៩" ជាមួយនិង American Depositary Receipt ( កំរិត ១ ) ដែលមានប្រត្តិបត្តការក្នុងទីផ្សារភាគហ៊ុននោះ ( សញ្ញាសម្គាល់៖ " AAGIY" ) ។

**ទំនាក់ទំនងសារព័ត៌មាន**

ម៉េង ដាណែត
ប្រធានផ្នែកទំនាក់ទំនងសាធារណៈ
អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក
Daneth-d.Meng@aia.com

**Sharon Dayan**
Global Marketing Director
023 965 731
sharond@medix-global.com